# "តំបន់ស"
# ជាការរំលោភយ៉ាងព្រហើនគោរកាច និងខុសច្បាប់ទៅលើបូរណភាពទឹកដីកម្ពុជា គឺជាប្រការមួយមិនអាចទទួលបានដាច់ខាត !

## នរោត្តម-សីហនុ

ប៉េកាំង, ថ្ងៃទី២៩ ឧសភា ២០០៥

(បកប្រែក្រៅផ្លូវការ)

ដោយ សុទ្ធ-ប៉ូលិន ★ ថ្ងៃទី១ មិថុនា ២០០៥

បើគេនិយាយត្រឹមតែអំពីផែនទីភូមិសាស្ត្រនៃប្រទេសកម្ពុជាទៅចុះ ដែលរាជរដ្ឋាភិបាលខ្មែរ <បានដាក់តម្កល់> កាលពីឆ្នាំ១៩៦៤ នៅអង្គការសហប្រជាជាតិ (ដែលមានរង្វាស់ពង្រួញ ១០០,០០០ដង) ។

( <u>កកន</u> ៖ ឆ្នាំ១៩៦៤ ជាឆ្នាំដែលសម្តេចសីហនុរៀបចំផ្តាច់ចំណងទូតជាមួយអាមេរិកាំង, កំពុងចាប់ផ្តើមអនុញ្ញាតឲ្យកងទ័ពយៀកកុងមកតាំងនៅជាអចិន្ត្រៃយ៍ នៅក្នុងព្រំដែនកម្ពុជាបច្ចុប្បន្ន... ហើយនិងកំពុងចាប់ផ្តើមកសាងជីវភាពថ្មីរបស់ទ្រង់ ជាតារាភាពយន្តជាមួយអ្នកម្នាងម៉ូនិក (ដូច្នេះស្តេចឡើកីនេះឥតដឹងអីទេអំពីព្រំដែន) ។ សូមអានអត្ថបទមួយរបស់លោក Jean Morice ស្រង់ចេញពីសៀវភៅ <កម្ពុជា- ពីសំណើចទៅដល់ការភិតភ័យតក្កមា> ៖ «តាមការពិត ស្តេចសីហនុបានក្បត់ជាតិរបស់ទ្រង់ តាំងតែពីពេលដែលទ្រង់បានអនុញ្ញាត ឲ្យកងទ័ពយៀកណាមខាងជើងនិងយៀកកុង មកតាំងនៅក្នុងទឹកដីកម្ពុជាម្ល៉េះ... (១៩៦៤) ។ គឺជាជំហានទី១ នៅលើមាគ៌ា ដែលនាំទៅដល់ថ្ងៃទី១៧មេសា១៩៧៥» (Cambodge, du sourire à l'horreur, page 432 ) ។

⌘

យោងតាមពាក្យសំដីរបស់ឯ.ឧ. សុខ-អាន, ឯ.ឧ. វ៉ារ-គឹមហុង និងឯ.ឧ. ឡុង-វីសាឡូ, វាមិនអាចមាននៅលើផែនទីបែបដូចនេះ នូវកន្លែង«តំបន់ស» សូម្បីតែបន្តិចបន្តួចក៏មិនអាចដែរ, ពោលគឺតំបន់ដែល«ព្រំប្រទល់ពិតប្រាកដ» រវាងកម្ពុជានិងអ្នកជិតខាងផ្ទាល់របស់ខ្លួនណាមួយមិនបានត្រូវ«អនុម័ត» ឬមាន«លក្ខណៈមិនច្បាស់លាស់», ឬក៏ត្រូវ«គូសវាសដោយរបៀបមិនជាក់លាក់ ឬដោយបណ្តោះអាសន្ន», ឬ«ក៏គ្មាននរណាស្គាល់» ឬ«គ្មាននរណាទទួលដឹងឮ» ពីរយៈប្រទេសកម្ពុជា ឬពីសំណាក់អ្នកជិតខាងផ្ទាល់របស់ខ្លួន ។

( <u>កកន</u> ៖ សីហនុនិយាយជាន់ជើងតែខ្លួនឯង... ប្រសិនបើព្រំប្រទល់ខ្មែរត្រូវគេទទួលស្គាល់អស់ហើយ ហេតុអ្វីបានជានៅក្នុងឆ្នាំ១៩៦៧-១៩៦៨ ស្តេចសីហនុបានខំប្រឹងប្រែងអំពាវនាវ ឲ្យអាមេរិកាំង រដ្ឋការវៀតណាមកុងវ៉ា (យួនខាងត្បូង) និងរាជាណាចក្រសៀម ទទួលស្គាល់បូរណភាពទឹកដីខ្មែរ ក្នុងក្របខ័ណ្ឌនៃព្រំប្រទល់បច្ចុប្បន្នខ្លាំងម្ល៉េះ ? ) ។

«តំបន់ស» គឺជាការប្រឌិតសុទ្ធសាធពីប្រទេសជិតខាងផ្ទាល់ «ក»ឬ«ខ»ឬ«គ» នៃប្រទេសកម្ពុជា ហើយត្រូវបណ្តាក់បន្ទុកទៅលើពួកខ្មែរដែលស្ថិតនៅក្រោមរណបនៃពួកអំណាចបរទេស «ក» ឬ «ខ» ឬ «គ» ។

⌘

«ខ្លួនខ្ញុំបានឡើងកាន់កាប់ព្រះរាជបល្ល័ង្កនៃប្រទេសកម្ពុជា នៅក្នុងឆ្នាំ១៩៤១, ហើយរហូតដល់រដ្ឋប្រហារលន់-នល់ នៃថ្ងៃ១៨មិនា១៩៧០, ខ្ញុំមិនដែលបានដឹងទាល់តែសោះថា នៅទីកន្លែងណាមួយនៅតាមជួរព្រំប្រទល់នៃប្រទេសខ្ញុំ វាមានតំបន់ណាមួយដែលត្រូវទាមទារដោយប្រទេសជិតខាង ។

( <u>កកន</u> ៖ សីហនុជាមនុស្សចេះធ្វើភ្លើ... ឬក៏ជាមនុស្សភ្លើធ្វើចេះ ? ចុះកោះត្រល់...យួនវាមិនទាមទារ? ហើយព្រះវិហារ...សៀមវាមិនទាមទារ? ចុះនៅក្នុងឆ្នាំ១៩៦៩... នៅជួរព្រំប្រទល់ដែនកម្ពុជាផ្នែកខាងកើត តាំងពីរតនៈគីរី, មណ្ឌលគីរី, ក្រចេះ, កំពង់ចាម, ស្វាយរៀង, ព្រៃវែង, តាកែវ, កំពត... មិនមែនជាជំរំទីតាំងយៀកកុងដ៏សម្បើមដាច់កន្ទុយភ្នែកទេឬ ?




ផែនទីបង្ហាញទីតាំងរបស់យៀកកុងនៅក្នុងទឹកដីខ្មែរទិសខាងកើត



ទន្នឹមជាឧត្តមសេនិយញ៉ឹក-ជូឡុង ស្តេចសីហនុ (ទី២ពីឆ្វេង) កំពុងបង្ហាញផែនទីទីតាំងរបស់យៀកកុងទៅពួកអ្នកកាសែត (28 Mars 1969)

ស្តេចសីហនុខ្លួនឯង បានប្រើឧត្តមសេនិយលន់-នល់ នាយសេនាធិការឲ្យធ្វើគំនូសទីតាំង អំពីយួនឈ្លានពានទាំងនេះ... ឲ្យធ្វើផែនទីមួយជាកិច្ចការសម្ងាត់របស់យោធា... ដោយមានគំនូសឆ្នូតៗសំដៅទៅតំបន់ព្រំប្រទល់ដែលពួកយៀកកុងបានមកតាំងនៅ...។ គឺមិនស្តេចសីហនុខ្លួនឯងទេឬ ដែលបានយកផែនទីសម្ងាត់របស់កងទ័ពនេះ ដែលមាន«តំបន់ឆ្នូត» មិនមែន«តំបន់ស»ទេ នៅព្រំប្រទល់ខាងកើតរបស់ខ្មែរ យកមកបោះផ្សាយនៅក្នុងទំព័រទស្សនាវដ្តីរដ្ឋ (Le Sangkum) នៅដើមឆ្នាំ១៩៦៩ ដោ

យមានសរសេរវិចារណកថាមួយដ៏ប្រិមប្រិយ ចុះហត្ថលេខាដោយនរោត្តម-សីហនុផ្ទាល់ មានចំណងជើងថា «ការរាតត្បាត» (La Curée) ដោយបញ្ជាក់ថា «ពេលអាមេរិកាំងចេញផុតពីដែនដីឥណ្ឌូចិន វៀតណាមខាងជើង នឹងធ្វើការរាតត្បាតទៅលើប្រទេសកម្ពុជាគ្មានសល់អ្វីឡើយ» ។ ម្តងឃើញដូចចេះ...ម្តងឃើញដូចភ្លើ ។ តាមពិតស្តេចសីហនុជាមនុស្សឆ្កួតសុទ្ធសាធ សមតែយកទៅឲ្យហ្វូបខ្សែភ្លើង ពីព្រោះលទ្ធផលចុងចប់ទៅ ប្រទេសកម្ពុជាត្រូវរលត់រលាយអស់, ទីក្រុងនិងខេត្តខ្មែរដែលបានសាងឡើងជិត១០០ឆ្នាំ នៅក្រោមរដ្ឋការបារាំង បានក្លាយទៅជាផេះ ។ ចំណែកប្រជាពលរដ្ឋខ្មែរបានត្រូវស្លាប់អស់២-៣លាននាក់ ដោយសារតែស្នាដៃរបស់មនុស្សឆ្កួត ដែលមានឈ្មោះថា នរោត្តម-សីហនុ ។ មនុស្សម្នាក់នេះ ជាមនុស្សឆ្កួតមែនទែន មិនមែនជាមនុស្ស«ឆ្កួតមានបញ្ញា»ដូចដែលគាត់បានអួតអាងនោះទេ ( un fou génial !! ) ។ ពីព្រោះថា នៅក្នុងឆ្នាំ១៩៦៩ ស្តេចសីហនុខ្លួនឯង ជាអ្នកប្រើលោកលន់-នល់ដេញយួន ។ ស្រាប់តែនៅឆ្នាំ១៩៧០ នៅពេលដែលលន់-នល់កំពុងជាប់ដៃធ្វើនយោបាយដេញយួន សីហនុចោទលន់-នល់ថាជាជនក្បត់ ។ ស្នាដៃ



ភ្នែកផាំ-យ៉ាំងដុងសម្លឹងស្តេចសីហនុ ជាភ្នែកមុតរបស់ឆ្កែចចកដែលចាំតែត្របាក់ស៊ីកូនចៀម... ចំណែកស្តេចសីហនុជាស្តេចភ្លីភ្លើ លើកដីឲ្យយួនហើយនឹកស្មានថាយួនជាអ្នកមានគុណ... ស្មានតែយួនវាជួយច្បាំងរំដោះពីលន់-នល់ហើយនិងអាមេរិកាំង ជាពិសេសស្មានតែយួនវាព្រមគោរពព្រំដែនខ្មែរ ដូចតាមពាក្យសន្យា ។

របស់ស្តេចសីហនុ គឺបានធ្វើប្រទេសកម្ពុជាឲ្យរលត់រលាយជាផេះ និងបណ្តាលឲ្យមានមហាសោកនាដកម្មនៃការពីឃាតរង្គាល (ថ្ងៃទី១៧មេសាឆ្នាំ១៩៧៥) ។ បើដូច្នោះហើយនៅក្នុងកាលៈទេសៈបច្ចុប្បន្ន នៅតែមានពួកជនដែលចង់លើក«អំណាចគ្រប់ប្រភេទ» ឲ្យសីហនុតទៅទៀត ។ យើងមានចម្ងល់ថា តើជនទាំងនេះជាជនជាតិខ្មែរ ឬក៏ជាជនជាតិយួន ឬក៏ជាពួក«ក្បាលយួនខ្លួនខ្មែរ» ?? (Cambodian body with a Vietnamese mind ?) ។

⌘

នៅក្នុងឆ្នាំ១៩៥៥, ប្រធានាធិបតី ង៉ោ-ឌិនយៀម នៃវៀតណាមខាងត្បូង, នៅព្រៃនគរ, បានថ្លែងប្រាប់ខ្ញុំថា កោះសមុទ្រនៅក្បែរក្រុងកែប គួរតែខ្ញុំ«ប្រគល់» (sic) ទៅឲ្យវៀតណាមរបស់គាត់វិញ (sic!) ។ ខ្ញុំក៏បានឆ្លើយតបទៅគាត់វិញថា (ពេលនោះយើងជជែកគ្នា នៅក្នុងវាំងរបស់គាត់នៅព្រៃនគរ) គឺគាត់ទេវិញទេ (ង៉ោ-ឌិនយៀម) ដែលត្រូវប្រគល់កោះត្រល់ និងកម្ពុជាក្រោមមកខ្មែរវិញ ។ តាំងពីពេលនោះមក ពួកង៉ោ-ឌិនយៀម, ង្វៀង-យ៉ាំងធីវ និងង្វៀង-កៅគី ។ល។ រហូតដល់ពេលខ្ញុំដួល«រលំ» នៅក្នុងឆ្នាំ១៩៧០ លែងហ៊ានទាមទារដីតែមួយចំណិតឬកោះណាមួយនៃ«ប្រទេសកម្ពុជារបស់ខ្ញុំ» ទៀតឡើយ ។
( កកន ÷ ចាំបាច់ទាមទារធ្វើអ្វី... បើពួកយួនខាងជើងនិងយៀកកុង ដែលជាយួនគ្នាវា មកនៅពេញព្រំប្រទល់ខាងកើតរួចទៅហើយ ។ ពួកយួនខាងជើងវាគោរពទទួលស្គាល់ដីខ្មែរ រួចហើយវាធ្វើការរំលោភត្រង់ៗតែម្តង ដូចតែជនជនជាតិចាមសូត្រធម៌ឲ្យសត្វគោ រួចហើយក៏ប្រហារយកសាច់ជាអាហារ ! ) ។

⌘

៦.ឌ. ចិនដ្រា (ឥណ្ឌា), អតីតប្រធាននៃគណៈកម្មាធិការអន្តរជាតិផ្ទៀកត្រួតពិនិត្យព្រំដែននៃ«ហ្សឺណែវ» «១៩៥៤» នៅរស់នៅឡើយក្នុងចំណោមយើង (សព្វថ្ងៃគាត់សំណាក់នៅប្រទេសអង់គ្លេស) ។ វរជនម្នាក់នេះអាចបញ្ជាក់ប្រាប់គេឯងថា នៅក្នុងសម័យសង្គមរាស្ត្រនិយម វាគ្មានកន្លែងព្រំដែនខ្មែរត្រង់ណាមួយសោះ ដែលមានលក្ខណៈមិនច្បាស់លាស់នោះទេ ។

⌘

វាមានរឿងអាស្រូវមួយតាំងពីឆ្នាំ១៩៧៩... ការបែងចែកទឹកទន្លេរបស់យើង ដោយមានទឹកទន្លេនេះមួយភាគនៅក្នុងដីកម្ពុជាយកទៅឲ្យវៀតណាម ។

⌘

រឿងចុងក្រោយបំផុត តែពុំមែនជារឿងតូចតាចទេ... ការបង្ខិត«ក្លោងទ្វារ» និង«ថ្មកំណត់ព្រំដែន» នៃប្រទេសជិតខាង ក, ខ, និងគ យ៉ាងជ្រៅ (រហូតដល់១៧គ.ម. ឬក៏លើសពីនោះទៅទៀត) ចូលមកក្នុងដីកម្ពុជា, ព្រមទាំងការជីកអូរប្រឡាយពីសំណាក់វៀតណាម, ការសង់មហាមាគ៌ា Highway ត្រង់ភ្លឹងពីសំណាក់ពួកថៃ ចូលជ្រៅមកក្នុងប្រទេសកម្ពុជា ដែលត្រូវគេចាត់ទុកថាជាព្រំដែនថ្មី រវាងប្រទេសកម្ពុជាដ៏អភ័ព្វ ហើយនិងពួកអ្នកជិតខាងដ៏មហិមា, សាធារណរដ្ឋសង្គមនិយមវៀតណាម, ប្រទេសថៃ ដោយកុំភ្លេចរាប់សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ។
( កកន ÷ ប្រទេសលាវមិនមែនជាមហាប្រទេសទេ ហើយក៏មិនដែលមានផលរមាស់អ្វីជាមួយខ្មែរដែរ តាំងពីសម័យបុរាណកាល ) ។

⌘

ដើម្បីវិលត្រឡប់មក«តំបន់ស»វិញ ពួកវៀត (វៀតកុង) អាចធ្វើឲ្យមានភ្លៀងផ្គរបានស្រេចតែអំពើចិត្ត ។ ពួកខ្មែរគ្មានសិទ្ធិនឹងធ្វើសកម្មភាពអ្វីទាល់តែសោះនៅទីនោះ ។

ក្នុងប្រការហៅឲ្យចំថា «សត្វឆ្មាជាសត្វឆ្មា», ដូចពាក្យស្លោកនៃប្រជាជនបារាំង, «តំបន់ស» គឺបានត្រូវប្រគល់ឲ្យយ៉ាងសុទ្ធសាធជាក់ស្តែង ពីសំណាក់អាជ្ញាធរខ្មែរ ទៅសាធារណរដ្ឋសង្គមនិយមវៀតណាម ដោយមាន«ការក្លែងបន្លំ»ដ៏គួរអាម៉ាស់... ថាជាតំបន់ដែលគេដាក់នៅលើតុនៃការចរចា...។

# កំណាត់អ្នកបកប្រែ

ស្តេចសីហនុ ជាមនុស្សឆ្កួតម៉្យាង ដែលគេពិបាកចាប់ថ្នាក់ជាទីបំផុត ពីព្រោះកាលណា បើកាលណាអ្នកផងសម្លឹងមើលទៅគាត់ ដែលកំពុងតែមានលក្ខណៈឆ្កួត... ស្រាប់តែគាត់មានឫកពាកែប្រែទៅជាមនុស្សសមរម្យធម្មតាម្នាក់ ចេះពោលពាក្យវាចាដែលស្របតាមវិចារណញ្ញាណ ។ ក៏ប៉ុន្តែនៅពេលអ្នកផង បែរភ្នែកចេញពីគាត់ គាត់ក៏ចាប់ផ្តើមអំពើឆ្កួតលីលារបស់គាត់តទៅទៀត ។

តទៅនេះជាអត្ថបទមួយ ដែលខ្ញុំបានសរសេរនៅក្នុងសៀវភៅសិក្សាស្រាវជ្រាវជាភាសាបារាំង «Cambodge, le Chemin de l'Apocalypse 1969-1970» (កម្ពុជា- មាគ៌ាទៅរកមហាអន្តរាយ) ថ្លែងពីឧក្រិដ្ឋកម្មបីយ៉ាង ដែលស្តេចសីហនុបានប្រព្រឹត្តទៅលើបញ្ហាសន្តិសុខនៃព្រំដែនកម្ពុជាក្នុងឆ្នាំ១៩៦៩ ហើយខ្ញុំបានបោះពុម្ពផ្សាយក្នុងទំព័រសារពត៌មាន «អង្គរបូរី» កាលពីឆ្នាំ១៩៩៦ ៖

«អំពើក្បត់

ទី១- នៅដើមឆ្នាំ១៩៦៩ សម្តេចព្រះប្រមុខរដ្ឋបានយករបាយការណ៍សម្ងាត់របស់ឧត្តមសេនីយលន់-នល់ ដោយមានផែនទីច្បាស់លាស់នៃទីតាំងយៀកកុងនៅក្នុងទឹកដីកម្ពុជា ទៅបោះផ្សាយនៅក្នុងទស្សនាវដ្តី Le Sangkum ។ តើគោលបំណងព្រះអង្គយ៉ាងណា ? តើព្រះអង្គបំរើផលប្រយោជន៍ខាងណា ដោយយកកិច្ចការសម្ងាត់របស់កងទ័ពខ្មែរដ៏សំខាន់បែបនេះ យកមកលាតត្រដាងជាសាធារណៈ ? តើសម្តេចសីហនុចង់ញុះញង់ពួកយោធារបស់ទ្រង់ ឲ្យមានកំហឹងនឹងយៀកកុង ឬក៏ផ្ទុយទៅវិញ ចង់ឲ្យពួកយោធារបស់ទ្រង់ត្រូវរំលាយចោល ដោយពួកសត្រូវសួរពូជ ? គឺថាសម្តេចពុំបានសម្លឹងទៅខាងអាមេរិកាំងនោះសោះទេ តែបានសម្លឹងទៅរកពួកខាងកុម្មុយនិស្តវៀតណាមវិញ ។ ស្តេចសីហនុចង់បានកេរ្តិ៍ឈ្មោះនិងសិរីល្អ (Glory) ជាមេដឹកនាំបដិវត្តន៍ ហើយកំពុងតែរៀបចំចាក់សម្លាប់ប្រទេសខ្លួនឯង ក្នុងប្រការឲ្យបានសំរេចជោគជ័យផ្ទាល់ខ្លួនរបស់ទ្រង់ ។ អនាគតបានបង្ហាញឲ្យឃើញថា... សម្តេចបានធ្វើការបំផ្លិចបំផ្លាញកំចាត់កងទ័ពរបស់ខ្លួនឯងឲ្យវិនាសសន្តិ... ដោយប្រើកម្លាំងខាងទ័ពខ្មាំងនៃប្រជាជាតិរបស់ទ្រង់ ។

«អំពើក្បត់ទី២- ពេញឆ្នាំ១៩៦៩ ជាពិសេសចាប់តាំងពីពាក់កណ្តាលឆ្នាំឡើងទៅ សម្តេចសីហនុបានបញ្ជាឲ្យកងទ័ពខ្មែរ ចាប់ពួកយៀកកុងពីព្រំប្រទល់មកថ្វាយទ្រង់ ។ រួចជាបន្ទាប់មក ព្រះអង្គក៏ចេញមុខការពារ



ពួកយៀកកុងទាំងអស់នេះ បានត្រូវគេចាប់យកមកបង្ហាញសីហនុ នៅឯវាំងភ្នំពេញ រួចបន្ទាប់មកត្រូវគាត់បញ្ជាឲ្យដោះលែងទៅវិញ ?!

ពួកយៀកកុងទាំងនេះ ដោយបញ្ជាឲ្យក្រសួងការបរទេសដោះលែងពួកវាទៅវិញ ? តើដើម្បីប្រយោជន៍អ្វីដែរ ដែលសម្តេចធ្វើការស្វះស្វែងដើម្បីប្រមាថបន្តោកបន្ទាបកងទ័ពរបស់ខ្លួនឯងបែបដូចនេះ ? តើទ្រង់ចង់បញ្ជូនដំណឹងទៅដល់ពួកយៀកកុង ថាទ្រង់មិនចូលចិត្ត ព្រមទាំងដាក់ទោស «ចំណាត់ការ» របស់ឧត្តមសេនីយលន់-នល់ នាយសេនាធិការរបស់យើង ? ពួកយៀកកុងទាំងនេះ ដែលបានត្រូវដោះលែងតាមផ្លូវការ ក៏បានត្រូវស្ថានទូតយៀកកុងនៅភ្នំពេញ ទទួលយកទៅឱបក្រសោប, ពួកគេក៏អាចដើរក្រវែលឆ្វៃលឆ្លាត់ពេញរាជធានីខ្មែរ ដូចហ្វូងឆ្កែចចក ដើរនៅក្នុងក្រោលចៀម ។ នេះគឺដោយសារតែព្រះតម្រិះនិងបញ្ញាបាធីរបស់ប្រមុខរដ្ឋខ្មែរ ។

«អំពើក្បត់ទី៣- នៅចុងឆ្នាំ១៩៦៩, សម្តេចសីហនុបានបញ្ជូនឲ្យគណៈកម្មាធិការអន្តរជាតិផ្នែកត្រួតពិនិត្យត្រឡប់ទៅវិញ ។ តាំងពីសន្និសិទហ្សឺណែវមក គណៈកម្មាធិការនេះមានភារកិច្ចដ៏ឧត្តុងឧត្តមផ្នែកខាងយាមល្បាតនិងធានាព្រំប្រទល់នៃកម្ពុជាយើង ។ គណៈកម្មាធិការនេះត្រូវតំណាងដោយក្រុមប្រតិភូនៃប្រទេសបី ឥណ្ឌា កាណាដា និងប៉ូឡូញ។ អ្នកសង្កេតការណ៍ទាំងនេះ ដែលដកស្រង់ចេញមកពីប្លុកទាំងពីរ ពុំមានអំណាចអ្វីអស្ចារ្យណាស់ណាទេ ក៏ប៉ុន្តែព្រំប្រទល់របស់យើងដែលមានគ្រោះថ្នាក់ដល់អាយុជីវិត ត្រូវការអ្នកយាមល្បាតទាំងនេះ ដូចតែដង្ហើមចេញចូល ។ ការបណ្តេញគណៈកម្មាធិការនេះឲ្យចាកចេញពីប្រទេសកម្ពុជា ទោះដោយប្រការណាក៏ដោយ ជាអំពើក្បត់មួយដ៏ថោកទាបបំផុត ។ ខ្ញុំបានដឹងនៅថ្ងៃក្រោយមកតាមរយៈសៀវភៅរបស់ Bernard Hamel (Sihanouk et le drame cambodgien) ថា នៅល្ងាចថ្ងៃ៣០ធ្នូ១៩៦៩ (គឺនៅចំពេលដែលសីហនុអះអាងថា ភ័យខ្លាចរដ្ឋប្រហារយោធា ពីសំណាក់អ្នកអង្គម្ចាស់ស៊ិសុវត្ថិ-សិរិមតៈ) ថា សម្តេចព្រះប្រមុខរដ្ឋកំពុងសេពសោយភោជនាហារយ៉ាងសប្បាយ ជាមួយនិងលោកប្រធានគណៈកម្មាធិការត្រួតពិនិត្យ (ជាតិប៉ូឡូញ) ដែលនឹងត្រូវចាកចេញពីប្រទេសកម្ពុជា។ គឺដូចតែព្រះអង្គបានជប់លៀងការហិនហោចនិងវិនាសកម្មរបើករបាញនៃព្រំដែនកម្ពុជារបស់យើងដូច្នោះឯង ។

«ដូច្នេះ នៅថ្ងៃដែលព្រះអង្គធ្វើដំណើរចាកចេញទៅប្រទេសបារាំង (៦មករា១៩៧០) អំពើបាបនិងឧក្រិដ្ឋកម្មទាំងប៉ុន្មាន ត្រូវព្រះអង្គបានបំពេញរួចអស់ហើយ ។ សម្តេចសីហនុព្រះប្រមុខរដ្ឋ បានលក់ជាតិរបស់ទ្រង់រួចទៅហើយ ។